Australian Government
Services Australia

# ទទួលបានភស្តុតាងនៃការចាក់វ៉ាក់សាំង COVID-19 របស់អ្នក

Immunisation history statement របស់អ្នកកត់ត្រាស្ថានភាពចាក់វ៉ាក់សាំង COVID-19 របស់អ្នក។

របៀបងាយស្រួលបំផុតក្នុងការទទួលបានរបាយការណ៍របស់អ្នកនៅលើអ៊ីនធឺណិតដោយប្រើមួយណាក៏បានដូចខាងក្រោម៖

- គណនី myGov របស់អ្នក
- កម្មវិធីទូរសព្ទចល័ត Express Plus Medicare។

## របៀបទទួលបាន immunisation history statement របស់អ្នក

## ប្រសិនបើអ្នកមានសិទ្ធិទទួលបាន Medicare

ប្រើប្រាស់ myGov៖

1. ចូលទៅគណនី myGov របស់អ្នក។
2. ជ្រើសរើសតំណលឿន **COVID-19 vaccination status**។
3. ជ្រើសរើសឈ្មោះរបស់អ្នក ហើយបន្ទាប់មក **View immunisation history statement (PDF)**។

ប្រើប្រាស់កម្មវិធីទូរសព្ទចល័ត Express Plus Medicare៖

1. ចូលទៅក្នុងកម្មវិធី។
2. ជ្រើសរើស **Immunisation history** ពី **Services**។
3. ជ្រើសរើសឈ្មោះរបស់អ្នក ហើយបន្ទាប់មក **View immunisation history statement**។

ប្រសិនបើអ្នកមិនអាចទទួលបាន immunisation history statement របស់អ្នកនៅលើអ៊ីនធឺណិតបានទេ ឬត្រូវការជំនួយ សូមទូរសព្ទទៅលេខ **1800 653 809**។

## ប្រសិនបើអ្នកមិនមានគណនី Medicare online ទេ

អ្នកត្រូវការតំណ Medicare ទៅគណនី myGov របស់អ្នកដើម្បីបង្កើតគណនី Medicare online របស់អ្នក។

ចូលទៅ ឬបង្កើតគណនី myGov របស់អ្នកនៅឯ **my.gov.au**

បន្ទាប់មកអ្នកអាចភ្ជាប់ Medicare ដោយប្រើតាមវិធីមួយខាងក្រោម៖

- លេខកាត Medicare របស់អ្នក និងព័ត៌មានពីប្រវត្តិ Medicare របស់អ្នក
- កូដភ្ជាប់ដែលយើងបានផ្តល់ឱ្យតាមទូរសព្ទ ឬនៅមជ្ឈមណ្ឌលសេវាកម្ម។

សម្រាប់ជំនួយភ្ជាប់ Medicare ទៅ myGov សូមទៅកាន់ **servicesaustralia.gov.au/medicareguides**

## របៀបទទួលបាន immunisation history statement នៅលើអ៊ីនធឺណិតរបស់អ្នក ប្រសិនបើអ្នកមិនមានសិទ្ធិទទួលបាន Medicare ទេ

អ្នកទទួលបាន immunisation history statement នៅអ៊ីនធឺណិតរបស់អ្នក ដោយប្រើប្រាស់ Individual Healthcare Identifiers (IHI) service តាមរយៈគណនី myGov របស់អ្នក។

អ្នកនឹងត្រូវផ្តល់ឱ្យយើងនូវព័ត៌មានលម្អិតពីឯកសារមួយនៃបណ្តាឯកសារសម្គាល់ខ្លួនដូចខាងក្រោម ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នក៖

- ○ លិខិតឆ្លងដែនរបស់អ្នក ដោយមានទិដ្ឋាការអូស្ត្រាលីមានសុពលភាពរបស់អ្នក
- ○ ប័ណ្ណបើកបរអូស្ត្រាលីរបស់អ្នក។

នៅពេលយើងបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នកហើយ យើងនឹងប្រើប្រាស់ព័ត៌មានលម្អិតរបស់អ្នកដើម្បីបង្កើត IHI របស់អ្នក។ យើងក៏នឹងភ្ជាប់ IHI service ទៅគណនី myGov account របស់អ្នកផងដែរ។ បន្ទាប់មកអ្នកអាចប្រើប្រាស់ IHI service ដើម្បីមើល immunisation history statement របស់អ្នក៖

1. ចូលទៅក្នុងគណនី myGov របស់អ្នក។
2. ជ្រើសរើសតំណលឿន **COVID-19 vaccination status**។
3. ជ្រើសរើសឈ្មោះរបស់អ្នក ហើយបន្ទាប់មក **View immunisation history statement (PDF)**។

## សម្រាប់ព័ត៌មានបន្ថែម

- ហៅទូរសព្ទទៅ Translating and Interpreting Service (TIS National) តាមលេខ 131 450 ដើម្បីនិយាយជាមួយយើង ជាភាសារបស់អ្នកអំពីសេវាកម្ម Medicare
- ទៅកាន់ **servicesaustralia.gov.au/covidvaccineproof** សម្រាប់ព័ត៌មានបន្ថែមជាភាសាអង់គ្លេស
- ទៅកាន់ **servicesaustralia.gov.au/yourlanguage** ដែលអ្នកអាចអាន ស្តាប់ ឬមើលវីដេអូ ដែលមានព័ត៌មានជាភាសារបស់អ្នក
- ទៅកាន់ **australia.gov.au** សម្រាប់បច្ចុប្បន្នភាព និងឱវាទចុងក្រោយបំផុតអំពី COVID-19
- ទៅទស្សនាមជ្ឈមណ្ឌលសេវាកម្ម។

ចំណាំ៖ ការហៅទូរសព្ទពីលេខទូរសព្ទផ្ទះទៅកាន់លេខ ‘13’ ពីកន្លែងណាមួយនៅក្នុងប្រទេសអូស្ត្រាលី ត្រូវបានគិតថ្លៃ តាមអត្រាថេរ។ អត្រានោះអាចប្រែប្រួលពីតម្លៃនៃការហៅទូរសព្ទនៅក្នុងតំបន់ ហើយក៏អាចប្រែប្រួលរវាងអ្នកផ្តល់សេវាទូរសព្ទនានា ផងដែរ។ ការហៅទូរសព្ទទៅលេខ ‘1800’ ពីលេខទូរសព្ទផ្ទះរបស់អ្នកគឺឥតគិតថ្លៃ។ ការហៅទូរសព្ទពីទូរសព្ទសាធារណៈ និងទូរសព្ទដៃ អាចត្រូវបានគិតម៉ោង ហើយអាចគិតថ្លៃតាមអត្រាកាន់តែខ្ពស់។

Australian Government
Services Australia

ENGLISH

# Get proof of your COVID-19 vaccination

Your immunisation history statement records your COVID-19 vaccination status.

The easiest way to get your statement is online using either:

- your myGov account
- the Express Plus Medicare mobile app.

## How to get your immunisation history statement if you are eligible for Medicare

Using myGov:

1. Sign in to your myGov account.
2. Select the **COVID-19 vaccination status** quick link.
3. Select your name, and then **View immunisation history statement (PDF)**.

Using the Express Plus Medicare mobile app:

1. Sign in to the app.
2. Select **Immunisation history** from **Services**.
3. Select your name, and then **View immunisation history statement**.

If you cannot get your immunisation history statement online or need help, call **1800 653 809**.

### If you do not have a Medicare online account

You need to link Medicare to your myGov account to set up your Medicare online account.

Sign in to, or create, your myGov account at **my.gov.au**

You can then link Medicare using either:

- your Medicare card number and information from your Medicare history
- a linking code we have given you either over the phone or at a service centre.

For help linking Medicare to myGov, go to **servicesaustralia.gov.au/medicareguides**

## How to get your immunisation history statement online if you are not eligible for Medicare

You can get your immunisation history statement online using the Individual Healthcare Identifiers (IHI) service through your myGov account.

You need to give us details from one of the following identity documents to verify your identity:

- your passport, with your valid Australian visa

- your Australian driver licence.

Once we have verified your identity, we will use your details to create your IHI. We will also link the IHI service to your myGov account. Then you can use the IHI service to view your immunisation history statement:

1. Sign in to your myGov account.
2. Select the **COVID-19 vaccination status** quick link.
3. Select your name, and then **View immunisation history statement (PDF)**.

## For more information

- call the Translating and Interpreting Service (TIS National) on **131 450** to speak with us in your language about Medicare services
- go to **servicesaustralia.gov.au/covidvaccineproof** for more information in English
- go to **servicesaustralia.gov.au/yourlanguage** where you can read, listen to or watch videos with information in your language
- go to **australia.gov.au** for the latest COVID-19 updates and advice
- visit a service centre.

Note: calls from your home phone to ‘13’ numbers from anywhere in Australia are charged at a fixed rate. That rate may vary from the price of a local call and may also vary between telephone service providers. Calls to ‘1800’ numbers from your home phone are free. Calls from public and mobile phones may be timed and charged at a higher rate.